# នាយកដ្ឋានសុខភាពអារម្មណ៍ North Sound

## គំរោងសុខភាពអារម្មណ៍ អ្នកជំងឺដេកពេទ្យបានបង់ប្រាក់ជាមុន សំរាប់

### ខោនធី Island, San Juan, Skagit, Snohomish, និងខោនធី Whatcom


### ការិយាល័យនាយកដ្ឋាន

117 North First Street, Suite 8
Mount Vernon, WA 98273

ទូរស័ព្ទ 360.416.7013
ទូរសារ 360.416.7017
លេខឥតចេញថ្លៃ 800.684.3555
TTY 360.419.9008
អ៊ីមែល nsmha@nsmha.org
លេខឥតចេញថ្លៃនៃអ្នកស៊ើបអង្កេតជំអួញ 888.336.6164
វ៉ិបសៃត៍ http://nsmha.org


កូនសៀវភៅឃោសនានេះគឺមានជាទំរង់អាចផ្ទេរយកបាន ចេញពីវ៉ិបសៃត៍របស់យើងនៅ http://nsmha.org ជាភាសា អង់គ្លេស, អេស្ប៉ាញ៉ុល, រុស្ស៊ី, ចិន, កូរ៉េ, លាវ, វៀតណាម, សូម៉ាលី, និងខ្មែរ ។

## តើបេសកកម្មនៃនាយកដ្ឋានសុខភាពអារម្មណ៍ North Sound (North Sound Mental Health Administration - NSMHA) មានអ្វីខ្លះ?

យើងរួបរួមគ្នា ដើម្បីធ្វើឲ្យសុខភាពអារម្មណ៍នៃសហគមន៍របស់យើងប្រសើរឡើង ហើយគាំទ្រការជាឡើងវិញ សំរាប់ប្រជាជនដែលមានជំងឺផ្លូវចិត្ត បានបំរើនៅក្នុងភូមិភាគ North Sound តាមរយៈការផ្តល់សេវាប្រកបដោយគុណភាពខ្ពង់ខ្ពស់ និងតាមសមត្ថភាពនៃវប្បធម៌ ។ វាគឺជាការទទួលខុសត្រូវនៃ NSMHA ដើម្បីធ្វើឲ្យប្រាកដប្រជាថា :

- សេវា(ការបំរើ)វិបត្តិសុខភាពអារម្មណ៍ គឺមាន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយអាទិត្យ សំរាប់មនុស្សគ្រប់ៗរូបនៅក្នុងភូមិភាគ ។
- លទ្ធភាពការទទួលសេវាសុខភាពអារម្មណ៍ ជាពេទ្យសាស្ត្រចាំបាច់យ៉ាងទាន់ពេលវេលា គឺមានសំរាប់មនុស្សគ្រប់ៗរូបដែលមានសិទ្ធិទទួល Medicaid ។
- សេវាទាំងអស់ស្របទៅតាមមាត្រដ្ឋានដ៏ខ្ពស់បំផុតនៃការថែទាំ ។
- ការព្យាបាលសុខភាពអារម្មណ៍ទាំងអស់ គឺបានបណ្តុលចិត្តដោយទាំងអតិថិជន និងតបឆ្លើយចំពោះសេចក្តីត្រូវការរបស់សាធារណជន ។
- ការព្យាបាលបានធ្វើទៅតាមភាពជាបុគ្គល បង្រួបបង្រួមកំឡាំងសហការជាមូលដ្ឋាន ជាមួយនឹងគ្រួសារ និងសហគមន៍ ដែលបើកទ្វារសំរាប់ការរើបឡើងវិញ និងសេចក្តីសង្ឃឹម ។
- សុវត្ថិភាពសាធារណៈ គឺជាការពិចារណាដ៏ឧត្តម ។
- ការថែទាំជាបន្តទៀត ស្របទៅតាមសេចក្តីត្រូវការនៃបុគ្គលទាំងមូល និងមានលទ្ធភាពទទួលសេវាផ្សេងៗទៀតឥតដាច់ឡើយ ។
- សេវាគឺយោគយល់ និងសមរម្យ តាមវប្បធម៌ ។

*យើងអញ្ជើញអ្នកឲ្យទៅចូលរួមក្នុងអង្គប្រជុំជាប្រចាំខែ នៃគណៈនាយក និងគណៈទីប្រឹក្សា ដែលប្រព្រឹត្តិនៅក្នុង (បន្ទប់ប្រជុំ) NSMHA Conference Room, 117 North First Street, Suite 8, Mount Vernon, Washington ។*

*អង្គប្រជុំនៃគណៈនាយក : ពីម៉ោង 1:30 - 3:00 នៅថ្ងៃប្រហស្បត៍ទីពីរ* រៀងរាល់ខែ ។*

*អង្គប្រជុំគណៈទីប្រឹក្សា : ពីម៉ោង 01:00 - 3:00 នៅថ្ងៃអង្គារទីមួយ* រៀងរាល់ខែ ។*

** សំរាប់ព័ត៌មានបន្ថែម ឬដើម្បីឲ្យដឹងច្បាស់អំពីថ្ងៃខែនៃការប្រជុំ សូមទូរស័ព្ទទៅ NSMHA តាមលេខ 360.416.7013 ឬមើលវ៉ិបសៃត៍របស់យើងនៅ* http://nsmha.org

## គុសេវាអតិថិជន

### តើខ្ញុំអាចទាក់ទងគុសេវាអតិថិជនរបស់ NSMHA ដោយដូចម្តេច?

រវាងម៉ោង 8:00 ព្រឹក និង 5:00 ល្ងាច ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ឥតរាប់ទូវថ្ងៃឈប់បុណ្យ : លេខឥតចេញថ្លៃ 1.800.684.3555/360.416.7013 សំរាប់អ្នកដែលពិការត្រចៀក/សំដី សូមទូរស័ព្ទទៅ NSMHA TTY 360.419.9008/សេវាបន្តសារ Washington តាមលេខ 1.800.833.6384

NSMHA នឹងផ្តល់ការបកប្រែភាសា សំរាប់អ្នកដែលពុំសូវមានចំណេះភាសាអង់គ្លេស ។

## ទស្សនៈនៃសេចក្តីសង្ឃឹម និងផ្លូវទៅរកការរើបឡើងវិញ

NSMHA បានប្តេជ្ញាចំពោះទស្សនៈនៃសេចក្តីសង្ឃឹម និងផ្លូវទៅរកការជារើបឡើងវិញ សំរាប់អតិថិជននៅក្នុងភូមិភាគ ។ ការរើបឡើងវិញគឺជាដំណើរមួយតាមរយៈដែលមនុស្សម្នាក់មានជំងឺផ្លូវចិត្ត អាចមានសេចក្តីសង្ឃឹមជាស្បើយឡើងវិញ គិតថាខ្លួនជាមនុស្សមានប្រយោជន៍ មានសេចក្តីថ្លៃថ្នូរ និងមានជីវិតប្រកបដោយអត្ថន័យ ។

## តើអ្នកណាមានសិទ្ធិទទួល?

អ្នក និងសមាជិកនៃគ្រួសាររបស់អ្នក ដែលរស់នៅក្នុងខោនធី Island, San Juan, Skagit, Whatcom ឬក្នុងខោនធី Snohomish ។

## តើមានប្រភេទនៃសេវាអ្វីខ្លះ?

- ការព្យាបាលធ្វើអន្តរាគមន៍គ្រួសៗ
- សេវាខាងវិបត្តិ
- ការគាំទ្រពេលថ្ងៃ
- ការព្យាបាលគ្រួសារ
- ការប្រមាណមើល និងការព្យាបាលជាដាច់ខ្សែក
- សេវាការព្យាបាលជាបុគ្គលម្នាក់ៗ
- ការព្យាបាលអ្នកជំងឺឥតដេកពេទ្យដោយហ្មត់ចត់
- សេវាការព្យាបាលជាក្រុម
- ធ្វើការប្រមាណមើល
- ការចាត់ចែងថ្នាំពេទ្យ
- ការត្រួតមើលថ្នាំពេទ្យ
- ការគាំទ្រដោយស្មើភាព/មណ្ឌលឈៀងចូល
- ការប្រមាណចិត្តវិជ្ជា
- ការចាត់ចែងករណីនៃការកសាងដំណើរជីវិតឡើងវិញ
- ការធ្វើឲ្យថៃទាំមួយរយៈកាល
- ផ្ទះក្លឹបសុខភាពអារម្មណ៍
- គាំទ្រខាងការងារ
- សេវាការធ្វើឲ្យមានស្ថិរភាព
- របៀបអប់រំភាពវិកលចរិត
- ការប្រមាណមើលប្រជាជនពិសេស
- សេវាខាងអាការស្តាប់ឮ និង/ឬ ការបកប្រែភាសា
- សេវាយ៉ាងសមរម្យតាមវប្បធម៌
- សេវាសុខភាពអារម្មណ៍ ក្នុងកាលនៅក្នុងលំនៅដ្ឋាន

សេវាដែលមានកត់ គឺមានសំរាប់អ្នកចុះឈ្មោះក្នុង Medicaid *និង* អ្នកដែលមានសិទ្ធិទទួល ដែលពុំមាន Medicaid ដរាបណាមានប្រភពជំនួយ ។

### តើសេវាអ្វីខ្លះដែល ***មិន*** រ៉ាប់រង?

- អ្វីដែលមិនជាអាសន្ន ឬយានជំនិះមិនមែនជា Medicaid ។
- ឱសថមានវេជ្ជបញ្ជាមិនមែនជាខាងវិកលចរិត ។
- សេវាចេញពីអ្នកផ្តល់នៅក្រៅបណ្តាញនៃ NSMHA លុះត្រាណាតែ NSMHA បានអនុញ្ញាត ។

### វ៉ិបសៃត៍របស់ NSMHA : http://nsmha.org

ដើម្បីរក្សាសុខភាពអារម្មណ៍សហគមន៍ឲ្យបានជ្រួតជ្រាប NSMHA បិទប្រកាស និងផ្សាយនៅលើវ៉ិបសៃត៍ នូវសំបុត្រសារព័ត៌មានដែលមានចំណងជើងថា *Recovery Around the Sound (ការរើបឡើងវិញនៅជុំវិញ Sound )* ។ ដើម្បីមើលវ៉ិបសៃត៍របស់យើង សូមទៅមើលនៅ http://nsmha.org ដើម្បីជាវសំបុត្រសារព័ត៌មានរបស់យើង សូមទូរស័ព្ទទៅលេខ 360.416.7013 / 1.800.684.3555 ឬផ្ញើអ៊ីមេល aroundthesound@nsmha.org ។

## អ្នកស៊ើបអង្កេតជំអូញ (Ombuds)

អ្នកស៊ើបអង្កេតជំអូញភូមិភាគ North Sound ផ្តល់ការគាំទ្រអតិថិជន សំរាប់មនុស្សគ្រប់ៗរូបដែលដាក់ពាក្យសុំ ឬទទួលសេវាសុខភាពអារម្មណ៍ជាសាធារណៈ នៅក្នុងខោនធី Island, San Juan, Skagit, Snohomish, និងខោនធី Whatcom ។ សូមទូរស័ព្ទទៅអ្នកស៊ើបអង្កេតជំអូញភូមិភាគ បើសិនជាអ្នកមានអារម្មណ៍ថាសិទ្ធិរបស់អ្នកត្រូវបានគេបំពាន ឬបើអ្នកមិនបានទទួលសេវាគ្រប់គ្រាន់ទេ ។ ការងាររបស់អ្នកស៊ើបអង្កេតជំអូញ គឺដើម្បីរកដំណោះស្រាយ ដែលស្របទៅតាមសេចក្តីត្រូវការរបស់អ្នក ។ សេវាទាំងនេះគឺជាការសំងាត់ ឥតគិតថ្លៃ ហើយច្បាប់ក៏ការពារអ្នក អំពីប្រភេទនៃការសងសឹកអ្វីមួយដែរ ។

### អ្នកស៊ើបអង្កេតជំអូញ*អាច* :

- គាំទ្រអតិថិជន ។
- ទទួលការត្អូញត្អែរពីអតិថិជន ឬដោយមានហត្ថលេខាការអនុញ្ញាតរបស់អតិថិជន ចេញពីគ្រួសារ ឬមិត្រភ័ក្តិរបស់គេ ។
- ស្តាប់ រក្សាទុកកំណត់ត្រា និងស៊ើបអង្កេតជំអូញ ។
- ជួយដោះស្រាយជំអូញជាក្រៅផ្លូវការ ដោយមានសេចក្តីយល់ព្រមពីអតិថិជន ។
- ស្រាវជ្រាវ និងស៊ើបអង្កេតហេតុការណ៍ ក្រឹត្យក្រម កិច្ចសន្យា ទំរង់ការ និងច្បាប់នានាជាប់ទាក់ទងចំពោះការត្អូញត្អែរ ។
- ជួយអតិថិជន តាមរយៈសារទុក្ខ(ការសើរើសេចក្តីទុក្ខកង្វល់) សវនាការរកយុត្តិធម៌ និងរបៀបតវ៉ា នៅពេលអាចអនុវត្តបាន ។

### អ្នកស៊ើបអង្កេតជំអូញ*មិនអាច* :

- ផ្តល់ឱវាទខាងច្បាប់ទេ ។
- ផ្តល់ការចាត់ចែងករណី ឬវិធីព្យាបាលទេ ។
- ផ្តល់មតិខាងពេទ្យ ឬការពិនិត្យព្យាបាលទេ ។

### តើខ្ញុំអាចទាក់ទងអ្នកស៊ើបអង្កេត ដោយរបៀបណា?

309 South Third Street, Mount Vernon WA 98273, 360.419.3391/1.888.336.6164
នៅពេលណាចាំបាច់ អ្នកស៊ើបអង្កេតអាចជួបជាមួយអ្នក នៅទីកន្លែងមួយដែលបានព្រមព្រៀងគ្នា ។

## តើជំងឺអារម្មណ៍ ជាទូទៅយ៉ាងណាដែរ?

ប្រជាជនអាមេរិកាំងប្រហែល 54 លាននាក់ បានរងវេទនាដោយសារវិបត្តិផ្លូវចិត្តមួយយ៉ាង ឬច្រើនជាងមួយប្រភេទ ។ ប្រជាជនអាមេរិកាំងជាមនុស្សពេញវ័យប្រហែល 19.6 លាននាក់ ឬ 9.2 ភាគរយ រងវេទនាអំពីជំងឺមួយដ៏ធ្ងន់ធ្ងរ ដែលរាំងរាយ៉ាងខ្លាំងក្លាជាមួយនឹងសកម្មភាពជីវិតសំខាន់ៗមួយ ឬច្រើនជាងមួយ ។ គេបានស្មានថាមានក្មេងៗ 2.7 លាននាក់ ដូចបានរាយការណ៍ដោយឪពុកម្តាយ/អ្នកអាណាព្យាបាលរបស់គេ ពិតជាបានរងវេទនាអំពីជំងឺនេះ ឬមានបញ្ហាខាងផ្លូវចិត្តធ្ងន់ធ្ងរ ដែលអាចនឹងបន្ទុចបង្អាក់ដល់ជីវិតនៃគ្រួសាររបស់គេ ឬសមត្ថភាពដើម្បីរៀនសូត្រ និងការចងមិត្រភាពរបស់គេ ។

## តើសញ្ញាប្រាប់ឲ្យដឹងជាមុន នៃជំងឺអារម្មណ៍មានអ្វីខ្លះ?

- ស្រយុតស្រយុងចិត្តត្រាំងត្រែង (ស្រងូតស្រងាត់ ឬងាយខឹង)
- ភាន់ភាំងគំនិត ឬការមមើមមាល
- គិតអំពីការសំឡាប់ខ្លួន/ការស្លាប់
- ល្ងិតល្ងៃជាខ្លាំង/ងងុយដេក ឬពុំអាចដេកលក់
- ដកខ្លួនចេញពីសង្គម
- ប្តូរជារំពេចក្នុងចរិតលក្ខណៈជាគោល
- ទំនាក់ទំនងខាងសង្គមចុះថយទៅៗ
- មានអារម្មណ៍ខ្ពស់ពេក ឬទាបពេក
- បង្ហាញឲ្យឃើញនូវឥរិយាបថប្លែក ជាអ្នកសើចមិនសមរម្យ ប្រើពាក្យ/ភាសាចំឡែក
- ពុំអាចស៊ូទ្រាំជាមួយនឹងបញ្ហា ឬសកម្មភាពប្រចាំថ្ងៃ
- គិតតែពីយំ/ពុំអាចយំចេញ
- មានអារម្មណ៍នៃការខឹងជាខ្លាំង អំពីនរណាម្នាក់ដែលធ្លាប់តែមានលក្ខណៈល្អ និងគួរឲ្យគោរព
- ចុះថយជាខ្លាំងក្នុងការសិក្សាមុខវិជ្ជា/កិច្ចការសិក្សា
- រំលោភសារធាតុញៀន

បើសិនជាអ្នក ឬសមាជិកគ្រួសាររបស់អ្នក កំពុងតែជួបប្រទះនូវសញ្ញានៃជំងឺផ្លូវចិត្ត សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នក ឬអ្នកវិជ្ជាជីវៈខាងសុខភាពអារម្មណ៍ សំរាប់ការប្រមាណមើល ។ អ្នកអាចទទួលសេវាសុខភាពអារម្មន៍ជាសាធារណៈ តាមរយៈ Access Line (ខ្សែលទ្ធភាពទាក់ទង) តាមលេខ 1.888.693.7200 ។

## តើសេចក្តីបង្គាប់ជាមុន សំរាប់សុខភាពអារម្មណ៍ ជាអ្វី?

វាគឺជាឯកសារមួយដែលបានសរសេរ ដែលរៀបរាប់អំពីអ្វីៗដែលអ្នកចង់បានឲ្យកើតឡើង បើសិនជាអ្នកក្លាយជាគ្មានសមត្ថភាពសំរេចចិត្តបានសោះឡើយ ដោយសារជំងឺផ្លូវចិត្ត ដែលការវិនិច្ឆ័យរបស់អ្នកបានអន់ថយ និង/ឬ អ្នកពុំអាចនិយាយប្រាស្រ័យទាក់ទងដោយប្រសិទ្ធិភាពបាន ។ វាអាចជំរាបអ្នកផ្សេងៗ អំពីការព្យាបាលអ្វីខ្លះដែលអ្នកចង់បាន ឬមិនចង់បាន ហើយវាអាចសំគាល់មនុស្សម្នាក់ដែលអ្នកបានឲ្យអាជ្ញា ដើម្បីធ្វើការសំរេចជំនួសអ្នក ។

## សិទ្ធិសុខភាពអារម្មណ៍របស់អ្នក

### ឋានៈជាមនុស្សម្នាក់ដែលទទួលសេវាសុខភាពអារម្មណ៍ជាសាធារណៈ តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះ?

- ដើម្បីឲ្យគេបានប្រព្រឹត្តមកលើ ដោយគោរព និងដោយថ្លៃថ្នូរ ។
- ដើម្បីឲ្យគេបានការពារ ភាពឯកជនរបស់អ្នក ។
- ដើម្បីជួយបង្កបង្កើត គំរោងនៃការថែទាំមួយ និងសេវានានា ដែលស្របតាមសេចក្តីត្រូវការរបស់អ្នក ។
- ដើម្បីចូលរួមក្នុងការសំរេច ស្តីអំពីការថែទាំសុខភាពអារម្មណ៍របស់អ្នក ។
- ដើម្បីទទួលសេវា ក្នុងទីកន្លែងមួយដែលឥតមានឧបសគ្គ (អាចចេញចូលបាន) ។
- ដើម្បីស្នើសុំព័ត៏មាន អំពីឈ្មោះ ទីកន្លែង លេខទូរស័ព្ទ និងភាសា សំរាប់ភ្នាក់ងារនៅតាមតំបន់ ។
- ដើម្បីទទួលចំនួន និងរយៈពេលនៃសេវាដែលអ្នកត្រូវការ ។
- ដើម្បីស្នើសុំព័ត៏មាន អំពីរចនា និងកិច្ចប្រតិបត្តិការនៃ NSMHA ។
- ដើម្បីទទួលសេវា ក្នុងរយៈពេល 2 ម៉ោង សំរាប់ការថែទាំជាអាសន្ន និងក្នុងពេល 24 ម៉ោង សំរាប់ការថែទាំជាបន្ទាន់ ។
- ឲ្យបានរួចចាក អំពីការប្រើនូវការដាក់ឲ្យនៅដាច់ឡែកពីគេ ឬការបង្ខាំង ។
- ដើម្បីទទួលសេវា សមរម្យតាមអាយុ និងវប្បធម៌ ។

- ដើម្បីឲ្យគេបានផ្តល់ឲ្យ នូវអ្នកបកប្រែមានវិញ្ញាបនបត្រ និងសំភារៈដែលបានបកប្រែ ដោយឥតអស់ថ្លៃដល់អ្នកឡើយ ។
- ដើម្បីយល់ដឹង អំពីជំរើសការព្យាបាលដែលមាន និងជារបៀបដទៃទៀត ។
- ដើម្បីបដិសេធ នូវការព្យាបាលអ្វីមួយដែលបានស្នើ ។
- ដើម្បីទទួលការថែទាំ ដែលមិនរើសអើងទាស់នឹងអ្នក (ដូចជា អាយុ ជាតិសាសន៍ ប្រភេទនៃជំងឺ) ។
- ដើម្បីឲ្យបានរួចចាក អំពីគោលបំណងនៃការរួមដំណេក ឬការឃាយីប្រភេទអ្វីមួយ ។
- ដើម្បីទទួលការពន្យល់ អំពីថ្នាំពេទ្យដែលបានចេញវេជ្ជបញ្ជាទាំងអស់ និងប្រតិកម្មបន្ទាប់បន្សំដែលអាចមាន ។
- ដើម្បីធ្វើសេចក្តីបង្គាប់ជាមុន ដែលថ្លែងនូវការជ្រើសរើសរបស់អ្នក និងចំណង់ចិត្តសំរាប់ការថែទាំសុខភាពអារម្មណ៍ ។
- ដើម្បីទទួលសេវា ប្រកបដោយគុណភាព ដែលជាពេទ្យសាស្រ្តចាំបាច់ ។
- ដើម្បីមានមតិទីពីរ ចេញពីអ្នកវិជ្ជាជីវៈខាងសុខភាពអារម្មណ៍ ។
- ដើម្បីប្តឹងសារទុក្ខ ជាមួយនឹងភ្នាក់ងាររបស់អ្នក ឬ NSMHA ។
- ដើម្បីប្តឹងតវ៉ា ជាមួយគំរោងសុខភាពអារម្មណ៍អ្នកជំងឺដេកពេទ្យបានបង់ប្រាក់ជាមុន (Prepaid Inpatient Health Plan - PIHP) ដោយយោងទៅលើសេចក្តីជូនដំណឹងនៃការសំរេច (សំរាប់អ្នកចុះឈ្មោះក្នុង Medicaid) ។
- ដើម្បីជ្រើសរើស អ្នកផ្តល់ការថែទាំសុខភាពអារម្មណ៍ ឬជ្រើសរើសអ្នកផ្តល់ការថែទាំម្នាក់ សំរាប់កូនរបស់អ្នកដែលមានអាយុក្រោមដប់បីឆ្នាំ ។
- ដើម្បីផ្លាស់ប្តូរ អ្នកផ្តល់ការថែទាំសុខភាពអារម្មណ៍ ក្នុងកំឡុងពេល 90 ថ្ងៃដំបូង ហើយជូនកាលញឹកញាប់ថែមទៀត ។
- ដើម្បីប្តឹង ស្នើសុំស្តីទីសវនាការ (យុត្តិធម៌) ។
- ដើម្បីស្នើសុំ និងទទួលសំណៅនៃកំណត់ត្រាសុខភាពរបស់អ្នក ហើយស្នើសុំធ្វើការកែប្រែ ។
- ដើម្បីឲ្យបានរួចចាក អំពីការសងសឹក ។
- ដើម្បីស្នើសុំ ក្រឹត្យក្រម និងទំរង់ការរបស់ NSMHA និងភ្នាក់ងារសុខភាពអារម្មណ៍សហគមន៍ (Community Mental Health Agency - CMHA) ដែលជាប់ទាក់ទិនទៅលើសិទ្ធិរបស់អ្នក ។

បុគ្គលទាំងឡាយក៏អាចចាប់ផ្តើមប្តឹងបញ្ហា នៃការមិនប្រព្រឹត្តតាមសេចក្តីដំរូវនៃសេចក្តីបង្គាប់ជាមុន សំរាប់ការថែទាំខាងផ្លូវចិត្ត ជាមួយនឹងផ្នែកខាងសុខភាពអារម្មណ៍ (Mental Health Division - MHD) តាមលេខ 1.888.713.6010 បានដែរ ។

## ទំនាក់ទំនង

ការគំរាមកំហែងជីវិតជាអាសន្ន ............................................................ 911

ការតបឆ្លើយវិបត្តិ ថែទាំ 24 ម៉ោង ............................................ 800.584.3578

ភាពមិនអាសន្ន និងការណាត់ពេលជួបជាដំបូង 888.693.7200

រាយការណ៍អំពីការគៃបន្លំ និងការរំលោភ ដោយទូរស័ព្ទទៅនាយកខាងការគៃបន្លំ និងការរំលោភ លោក Charles Benjamin តាមលេខ 1.800.684.3555 / 360.416.7013 ឬផ្ញើអ៊ីមៀលទៅ : charles_benjamin@nsmha.org ។ អ្នកក៏អាចរាយការណ៍ដោយមិនបញ្ចេញឈ្មោះដែរ ។

## អ្នកផ្តល់បានចុះក្នុងត្រាជាមួយ NSMHA

### ខោនធី Island

| | |
|---|---|
| Compass Health, Camano Island | 360.387.2736/1.800.457.9303 |
| Compass Health, Coupeville | 360.678.5555/1.800.457.9303 |

### ខោនធី San Juan

| | |
|---|---|
| Compass Health | 360.378.2669/1.800.457.9303 |

## ខោនធី Skagit

| | |
|---|---|
| Catholic Community Services | 360.856.3054/1.888.504.9992 |
| Compass  Health | 360.419.3500/1.800.457.9303 |
| Sea Mar Clinic | 360.428.8912/1.866.923.2312 |
| Sunrise Services | 360.336.3762/1.888.774.9658 |

## ខោនធី Snohomish

| | |
|---|---|
| Compass Health | 425.349.6200/1.800.457.9303 |
| bridgeways | 425.513.8213/1.877.355.8668 |
| Sea Mar Clinic | 425.347.5415/1.866.923.2312 |
| Catholic Community Services | 425.257.2111/1.888.504.9996 |
| Sunrise Services | 425.347.3149/1.888.774.9658 |

## ខោនធី Whatcom

| | |
|---|---|
| Whatcom Counseling & Psychiatric Clinic | 360.676.2220/1.888.311.0120 |
| Catholic Community Services | 360.676.2164/1.888.504.2221 |
| Lake Whatcom Center | 360.676.6000/1.888.676.6002 |
| Sea Mar Clinic | 360.734.5458/1.866.923.2312 |
| Interfaith Community Health Clinic | 360.676.6177/1.877.235.6850 |

## សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅអ្នកសំរបសំរួលសុខភាពអារម្មណ៍នៅក្នុងខោនធីរបស់អ្នក :

| | |
|---|---|
| អ្នកសំរបសំរួល ខោនធី Island | 360.678.7881 |
| អ្នកសំរបសំរួល ខោនធី San Juan | 360.378.4474 |
| អ្នកសំរបសំរួល ខោនធី Skagit | 360.336.9395 |
| អ្នកសំរបសំរួល ខោនធី Snohomish | 425.388.7200 |
| អ្នកសំរបសំរួល ខោនធី Whatcom | 360.676.6724 |

ភ្នាក់ងារនៅក្រៅភូមិភាគ North Sound ដែលស្វែងរកការបញ្ជាក់ និង/ឬ ការយល់ព្រម សំរាប់បុគ្គលដែលបានរ៉ាប់រងដោយ North Sound Prepaid Inpatient Mental Health Plan អាចទូរស័ព្ទទៅលេខ 1.888.693.7200 (ខ្សែលទ្ធភាពទាក់ទង) ។